# Microsoft License Terms

**បានធ្វើបច្ចុប្បន្នភាពចុងក្រោយក្នុងខែធ្នូឆ្នាំ 2016**

**លក្ខខណ្ឌអាជ្ញាបណ្ណសុហ្វវែរMICROSOFT**

**ប្រព័ន្ធប្រតិបត្តិការWINDOWS**

---

**បើអ្នករស់នៅក្នុង (ឬក៏បើកន្លែងគោលនៃអាជីវកម្មរបស់អ្នកស្ថិតក្នុង) សហរដ្ឋអាមេរិកសូមអានឧបញ្ញត្តិអំពីមជ្ឈត្តវិនិច្ឆ័យជាប់កាតព្វកិច្ចនិងការលះបង់ចំណាត់ការជាក្រុមក្នុងប្រការ 10. ដែលវានឹងប៉ះពាល់អំពីរបៀបដោះស្រាយទំនាស់។**

**សូមអរគុណអ្នកសម្រាប់ការជ្រើសរើសMicrosoft!**

អាស្រ័យលើរបៀបដែលអ្នកបានទទួលសុហ្វវែរWindows នេះគឺជាកិច្ចព្រមព្រៀងអាជ្ញាបណ្ណរវាង (i) អ្នកនិងឧស្សាហករឧបករណ៍ឬក៏អ្នកដំឡើងសុហ្វវែរដែលចែកចាយសុហ្វវែរនេះជាមួយឧបករណ៍របស់អ្នក; ឬ (ii) អ្នកនិងMicrosoft Corporation (ឬក៏សម្ព័ន្ធរបស់ខ្លួនណាមួយអាស្រ័យលើកន្លែងដែលអ្នករស់នៅឬបើជាអាជីវកម្មគឺកន្លែងគោលដែលអាជីវកម្មរបស់អ្នកស្ថិតនៅ) បើអ្នកបានទទួលសុហ្វវែរនេះពីអ្នកលក់រាយ។ Microsoft គឺជាឧស្សាហករឧបករណ៍សម្រាប់ឧបករណ៍ដែលMicrosoft ឬសម្ព័ន្ធមួយរបស់ខ្លួនណាមួយបានផលិតហើយMicrosoft គឺជាអ្នកលក់រាយបើអ្នកបានទទួលសុហ្វវែរនេះដោយផ្ទាល់ពីMicrosoft។

កិច្ចព្រមព្រៀងនេះពណ៌នាពីសិទ្ធិរបស់អ្នកនិងលក្ខខណ្ឌដែលអ្នកអាចប្រើសុហ្វវែរWindows។អ្នកគួរត្រួតពិនិត្យកិច្ចព្រមព្រៀងទាំងមូលរួមទាំងលក្ខខណ្ឌអាជ្ញាបណ្ណបំពេញបន្ថែមទាំងឡាយដែលអមជាមួយសុហ្វវែរនេះនិងលក្ខខណ្ឌដែលបានតនានាដោយសារលក្ខខណ្ឌទាំងអស់នោះមានសារៈសំខាន់ណាស់ហើយរួមគ្នាបង្កើតបានជាកិច្ចព្រមព្រៀងនេះដែលនឹងអនុវត្តចំពោះអ្នក។អ្នកអាចត្រួតពិនិត្យលក្ខខណ្ឌដែលបានតដោយបិទភ្ជាប់តំណ (aka.ms/) ទៅក្នុងវិនដូរប្រោវស៊ី។

**ដោយយល់ព្រមទទួលលក្ខខណ្ឌនេះឬដោយប្រើសុហ្វវែរនេះអ្នកយល់ព្រមតាមលក្ខខណ្ឌទាំងអស់នេះព្រមទាំងយល់ព្រមចំពោះការបញ្ជូនព័ត៌មានមួយចំនួនក្នុងអំឡុងពេលបើកដំណើរការនិងក្នុងអំឡុងពេលអ្នកប្រើសុហ្វវែរនេះដូចក្នុងសេចក្តីថ្លែងការណ៍ពីភាពឯកជនដែលបានពណ៌នាក្នុងប្រការ 3។បើអ្នកមិនយល់ព្រមទទួលនិងអនុលោមតាមលក្ខខណ្ឌទាំងនេះទេអ្នកមិនត្រូវប្រើសុហ្វវែរនេះឬមុខងាររបស់វាឡើយ។**អ្នកអាចទាក់ទងឧស្សាហករឧបករណ៍ឬអ្នកដំឡើងឬក៏អ្នកលក់រាយរបស់អ្នកបើអ្នកបានទិញសុហ្វវែរនេះដោយផ្ទាល់ដើម្បីដឹងពីគោលការណ៍ប្រគល់ត្រឡប់វិញនិងប្រគល់សុហ្វវែរនេះឬឧបករណ៍ត្រឡប់វិញដើម្បីទទួលប្រាក់សំណងវិញឬឥណទាននៅក្រោមគោលការណ៍នោះ។អ្នកត្រូវតែអនុលោមតាមគោលការណ៍នោះដែលអាចតម្រូវឲ្យអ្នកប្រគល់ត្រឡប់សុហ្វវែរនេះជាមួយឧបករណ៍ទាំងមូលដែលបានដំឡើងសុហ្វវែរលើនោះដើម្បីទទួលប្រាក់សំណងវិញឬឥណទានបើមាន។

**1.ទិដ្ឋភាពទូទៅ៖**

**a.លទ្ធភាពអាចអនុវត្តបាន៖**កិច្ចព្រមព្រៀងនេះអនុវត្តចំពោះសុហ្វវែរWindows ដែលត្រូវបានដំឡើងជាមុនលើឧបករណ៍របស់អ្នកឬបានទទួលពីអ្នកលក់រាយនិងបានដំឡើងដោយអ្នក, មេឌៀដែលផ្ទុកសុហ្វវែរដែលអ្នកបានទទួល (បើមាន), ពុម្ពអក្សរនានា, អាយខុន, រូបឬឯកសារសំឡេងដែលបានរួមបញ្ចូលជាមួយសុហ្វវែរព្រមទាំងបច្ចុប្បន្នភាពរបស់Microsoft, ការបំពេញបន្ថែមឬសេវានានាសម្រាប់សុហ្វវែរនោះលុះត្រាតែលក្ខខណ្ឌផ្សេងទៀតអមមកជាមួយពួកវា។វាក៏នឹងអនុវត្តផងដែរចំពោះកម្មវិធីWindows ដែលអភិវឌ្ឍដោយMicrosoft ដែលផ្តល់លទ្ធភាពធ្វើមុខងារដូចជាសំបុត្រទំនាក់ទំនងតន្ត្រីនិងរូបថតដែលបានរួមបញ្ចូលជាមួយនិងជាផ្នែកមួយរបស់Windows។បើកិច្ចព្រមព្រៀងនេះមានលក្ខខណ្ឌពាក់ព័ន្ធនឹងមុខងារឬសេវាដែលមិនមានលើឧបករណ៍របស់អ្នកនោះលក្ខខណ្ឌទាំងនោះមិនអនុវត្តឡើយ។

**b.លក្ខខណ្ឌបន្ថែមទៀត៖**លក្ខខណ្ឌបន្ថែមរបស់Microsoft និងតតីយភាគីអាចអនុវត្តចំពោះការប្រើរបស់អ្នកលើមុខងារសេវានិងកម្មវិធីមួយចំនួនអាស្រ័យលើសមត្ថភាពរបស់ឧបករណ៍អ្នករបៀបកំណត់រចនាសម្ព័ន្ធវានិងរបៀបដែលអ្នកប្រើវា។សូមប្រាកដថាអានលក្ខខណ្ឌទាំងនេះ។

(i)កម្មវិធីWindows ខ្លះផ្តល់ចំណុចចូលប្រើឬផ្អែកលើសេវាលើបណ្តាញហើយពេលខ្លះការប្រើសេវាទាំងនោះស្ថិតក្រោមលក្ខខណ្ឌដាច់ដោយឡែកនិងគោលការណ៍ភាពឯកជនដូចជាកិច្ចព្រមព្រៀងសេវាMicrosoft (aka.ms/msa)។អ្នកអាចបង្ហាញលក្ខខណ្ឌទាំងនេះនិងគោលការណ៍នានាដោយមើលលក្ខខណ្ឌនៃការប្រើសេវាឬការកំណត់របស់កម្មវិធីតាមភាពសមស្រប។សេវាខ្លះអាចមិនមានក្នុងតំបន់ទាំងអស់ឡើយ។

(ii)Microsoft, ឧស្សាហករឬអ្នកដំឡើងអាចរួមបញ្ចូលកម្មវិធីបន្ថែមដែលនឹងស្ថិតក្រោមលក្ខខណ្ឌអាជ្ញាបណ្ណដាច់ដោយឡែកព្រមទាំងគោលការណ៍ភាពឯកជន។

(iii)សុហ្វវែរនេះរួមបញ្ចូលAdobe Flash Player ដែលបានទទួលអាជ្ញាបណ្ណក្រោមលក្ខខណ្ឌនានាពីAdobe Systems Incorporated នៅ (aka.ms/adobeflash)។Adobe និងFlash គឺជាពាណិជ្ជសញ្ញាដែលបានចុះបញ្ជីឬជាពាណិជ្ជសញ្ញារបស់Adobe Systems Incorporated នៅសហរដ្ឋអាមេរិកនិង/ឬប្រទេសផ្សេងទៀត។

(iv)សុហ្វវែរនេះអាចរួមបញ្ចូលកម្មវិធីរបស់តតីយភាគីដែលផ្តល់អាជ្ញាបណ្ណជូនអ្នកក្រោមកិច្ចព្រមព្រៀងនេះឬក្រោមលក្ខខណ្ឌផ្ទាល់ខ្លួនរបស់ពួកគេ។លក្ខខណ្ឌអាជ្ញាបណ្ណសេចក្តីជូនដំណឹងនិងការទទួលស្គាល់បើមានសម្រាប់កម្មវិធីតតីយភាគីអាចបង្ហាញនៅ (aka.ms/thirdpartynotices)។

(v)ក្រោមវិសាលភាពដែលបានរួមបញ្ចូលជាមួយWindows កម្មវិធីWord, Excel, PowerPoint និងOneNote ត្រូវបានផ្តល់អាជ្ញាបណ្ណសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នកមិនមែនពាណិជ្ជកម្មប៉ុណ្ណោះលុះត្រាតែអ្នកមានសិទ្ធិនៃការប្រើប្រាស់លក្ខណៈពាណិជ្ជកម្មក្រោមកិច្ចព្រមព្រៀងដាច់ដោយឡែក។

**2.សិទ្ធិនៃការដំឡើងនិងការប្រើប្រាស់៖**

**a.អាជ្ញាបណ្ណ៖**សុហ្វវែរនេះបានទទួលអាជ្ញាបណ្ណមិនមែនត្រូវបានលក់ឡើយ។ក្រោមកិច្ចព្រមព្រៀងនេះ យើងផ្ដល់ជូនអ្នកនូវសិទ្ធិក្នុងការដំឡើងនិងដំណើរការវត្ថុបង្ហាញនៃសុហ្វវែរនេះលើឧបករណ៍របស់អ្នក (ឧបករណ៍ដែលបានទទួលអាជ្ញាបណ្ណ) សម្រាប់ការប្រើប្រាស់ដោយបុគ្គលម្នាក់ក្នុងពេលមួយឲ្យតែអ្នកអនុលោមតាមលក្ខខណ្ឌទាំងអស់នៃកិច្ចព្រមព្រៀងនេះ។បច្ចុប្បន្នភាពឬការដំឡើងថ្នាក់ពីសុហ្វវែរក្លែងក្លាយជាមួយសុហ្វវែរពីMicrosoft ឬប្រភពដែលទទួលការអនុញ្ញាតមិនធ្វើឲ្យកំណែដើមរបស់អ្នកឬកំណែដែលបានធ្វើបច្ចុប្បន្នភាព/បានដំឡើងថ្នាក់ក្លាយជាសុហ្វវែរមែនទែនឡើយហើយក្នុងស្ថានភាពនោះអ្នកមិនមានអាជ្ញាបណ្ណក្នុងការប្រើសុហ្វវែរនេះទេ។

**b.ឧបករណ៍៖**ក្នុងកិច្ចព្រមព្រៀងនេះ“ឧបករណ៍” មានន័យថាប្រព័ន្ធហាដវែរ (មិនថាជាក់ស្ដែងឬនិម្មិតឡើយ) ដែលមានឧបករណ៍ឃ្លាំងផ្ទុកខាងក្នុងដែលអាចដំណើរការសុហ្វវែរនេះ។ ការបែងចែកឬការពុះហាដវែរត្រូវបានចាត់ទុកថាជាឧបករណ៍មួយ។

**c.កំហិត៖**ឧស្សាហករឬអ្នកដំឡើងនិងMicrosoft សូមរក្សាសិទ្ធិទាំងអស់ (ដូចជាសិទ្ធិក្រោមច្បាប់កម្មសិទ្ធិបញ្ញា) ដែលមិនបានបញ្ជាក់យ៉ាងច្បាស់ក្នុងកិច្ចព្រមព្រៀងនេះ។ឧទាហរណ៍អាជ្ញាបណ្ណនេះមិនផ្ដល់ជូនអ្នកនូវសិទ្ធិណាមួយក្នុងការ (ហើយអ្នកមិនត្រូវ)៖

(i)ប្រើឬធ្វើនិម្មិតកម្មមុខងារនៃសុហ្វវែរនេះដាច់ដោយឡែកពីគ្នា;

(ii)ផ្សព្វផ្សាយចម្លង (ក្រៅពីសំណៅចម្លងទុកដែលទទួលការអនុញ្ញាត) ជួលឬឲ្យខ្ចីសុហ្វវែរនេះ;

(iii)ផ្ទេរសុហ្វវែរនេះ (លើកលែងតែបានអនុញ្ញាតដោយកិច្ចព្រមព្រៀងនេះ);

(iv)ធ្វើការជុំវិញកំហិតឬដែនកំណត់បច្ចេកទេសណាមួយក្នុងសុហ្វវែរនេះ;

(v)ប្រើសុហ្វវែរនេះជាសុហ្វវែរសឺវើសម្រាប់ហូស្ដិងពាណិជ្ជកម្ម, ធ្វើឲ្យមានសុហ្វវែរនេះសម្រាប់ការប្រើក្នុងពេលដំណាលគ្នាដោយអ្នកប្រើប្រាស់ច្រើនលើបណ្ដាញ, ដំឡើងសុហ្វវែរនេះលើសឺវើនិងអនុញ្ញាតឲ្យអ្នកប្រើប្រាស់ចូលប្រើវាពីចម្ងាយឬដំឡើងសុហ្វវែរនេះលើឧបករណ៍សម្រាប់ការប្រើតែដោយអ្នកប្រើប្រាស់ពីចម្ងាយ;

(vi)វិស្វកម្មបញ្ច្រាស់ការរុះរើឬការដោះបង្គុំសុហ្វវែរឬក៏ការប៉ុនប៉ងធ្វើដូច្នេះលើកលែងនិងក្រោមវិសាលភាពដែលកំហិតទាំងនេះ (a) ត្រូវបានអនុញ្ញាតដោយច្បាប់ជាធរមាន; (b) អនុញ្ញាតដោយលក្ខខណ្ឌផ្ដល់អាជ្ញាបណ្ណដែលគ្របដណ្ដប់លើការប្រើប្រាស់សមាសភាពប្រភពបើកទូលាយដែលអាចរួមបញ្ចូលជាមួយសុហ្វវែរនេះ; ឬ (c) តម្រូវឲ្យបំបាត់កំហុសការផ្លាស់ប្ដូរចំពោះការទទួលខុសត្រូវទាំងឡាយដែលបានផ្ដល់អាជ្ញាបណ្ណក្រោមអាជ្ញាបណ្ណសាធារណៈទូទៅនៃអ្នកជួលGNU ដែលអាចរួមបញ្ចូលជាមួយនិងតភ្ជាប់ជាមួយដោយសុហ្វវែរនេះ; និង

(vii)នៅពេលប្រើមុខងារផ្អែកលើអ៊ីនធឺណិតអ្នកមិនត្រូវប្រើមុខងារទាំងនោះតាមវិធីណាមួយដែលអាចរំខានដល់នរណាម្នាក់ផ្សេងទៀតដែលប្រើពួកវាឡើយឬក៏ព្យាយាមចូលប្រើឬប្រើសេវានានាទិន្នន័យគណនីឬបណ្តាញក្នុងលក្ខណៈមិនទទួលការអនុញ្ញាត។

**d.ស៊ីណែរីយ៉ូនៃការប្រើច្រើន៖**

(i)**កំណែច្រើន៖**បើនៅពេលទទួលសុហ្វវែរនេះអ្នកបានទទួលសុហ្វវែរដែលមានកំណែច្រើន (ដូចជាកំណែ32-bit និង64-bit) អ្នកអាចដំឡើងនិងបើកដំណើរការកំណែទាំងនោះមួយប៉ុណ្ណោះនៅពេលមួយ។

(ii)**ការភ្ជាប់ច្រើនឬផ្តុំ៖**ហាដវែរឬសុហ្វវែរដែលអ្នកប្រើដើម្បីធ្វើពហុគុណឬផ្តុំការភ្ជាប់ឬបន្ថយចំនួននៃឧបករណ៍ឬអ្នកប្រើប្រាស់ដែលចូលប្រើឬប្រើសុហ្វវែរមិនបន្ថយចំនួននៃអាជ្ញាបណ្ណដែលអ្នកត្រូវការឡើយ។អ្នកអាចប្រើហាដវែរឬសុហ្វវែរនោះតែក្នុងករណីដែលអ្នកមានអាជ្ញាបណ្ណសម្រាប់វត្ថុបង្ហាញនីមួយៗនៃសុហ្វវែរដែលអ្នកកំពុងប្រើប៉ុណ្ណោះ។

(iii)**ការភ្ជាប់ឧបករណ៍៖**អ្នកអាចអនុញ្ញាតឲ្យឧបករណ៍ផ្សេងទៀតដល់ទៅ20ចូលប្រើសុហ្វវែរដែលបានដំឡើងលើឧបករណ៍ដែលមានអាជ្ញាបណ្ណក្នុងគោលបំណងនៃការប្រើមុខងារសុហ្វវែរទាំងនេះ៖សេវាឯកសារ, សេវាបោះពុម្ព, សេវាព័ត៌មានអ៊ីនធឺណិតនិងការចែករំលែកការភ្ជាប់អ៊ីនធឺណិតព្រមទាំងសេវាទូរសព្ទលើឧបករណ៍ដែលមានអាជ្ញាបណ្ណ។អ្នកអាចអនុញ្ញាតឲ្យឧបករណ៍មួយចំនួនចូលប្រើសុហ្វវែរលើឧបករណ៍ដែលមានអាជ្ញាបណ្ណដើម្បីធ្វើសមកាលទិន្នន័យរវាងឧបករណ៍។ទោះជាយ៉ាងនេះក្តីផ្នែកនេះមិនមានន័យថាអ្នកមានសិទ្ធិក្នុងការដំឡើងសុហ្វវែរឬប្រើមុខងារចម្បងនៃសុហ្វវែរនោះឡើយ (ក្រៅពីមុខងារដែលបានរាយក្នុងផ្នែកនេះ) លើឧបករណ៍ផ្សេងទៀតទាំងនេះណាមួយ។

(iv)**ការប្រើក្នុងបរិស្ថាននិម្មិត៖**អាជ្ញាបណ្ណនេះអនុញ្ញាតឲ្យអ្នកដំឡើងវត្ថុបង្ហាញនៃសុហ្វវែរមួយប៉ុណ្ណោះសម្រាប់ការប្រើលើឧបករណ៍មួយមិនថាឧបករណ៍នោះជាក់ស្តែងឬនិម្មិតឡើយ។បើអ្នកចង់ប្រើសុហ្វវែរលើឧបករណ៍និម្មិតលើសពីមួយអ្នកត្រូវតែទទួលអាជ្ញាបណ្ណដាច់ដោយឡែកសម្រាប់វត្ថុបង្ហាញនីមួយៗ។

(v)**ការចូលប្រើពីចម្ងាយ៖**មិនលើសពីរៀងរាល់90ថ្ងៃម្តងអ្នកអាចចាត់តាំងអ្នកប្រើប្រាស់ទោលម្នាក់ដែលប្រើឧបករណ៍ដែលមានអាជ្ញាបណ្ណជាក់ស្តែងជាអ្នកប្រើប្រាស់ដែលបានទទួលអាជ្ញាបណ្ណ។អ្នកប្រើប្រាស់ដែលបានទទួលអាជ្ញាបណ្ណអាចចូលប្រើឧបករណ៍ដែលមានអាជ្ញាបណ្ណពីឧបករណ៍ផ្សេងទៀតដោយប្រើបច្ចេកវិទ្យាចូលប្រើពីចម្ងាយ។នៅពេលផ្សេងគ្នាអ្នកប្រើប្រាស់ដទៃទៀតអាចចូលប្រើឧបករណ៍ដែលមានអាជ្ញាបណ្ណពីឧបករណ៍មួយទៀតដោយប្រើបច្ចេកវិទ្យាចូលប្រើពីចម្ងាយប៉ុន្តែតែលើឧបករណ៍ដែលមានអាជ្ញាបណ្ណដាច់ដោយឡែកប៉ុណ្ណោះដើម្បីដំណើរការសុហ្វវែរដែលមានកំណែដូចគ្នាឬខ្ពស់ជាងនេះ។

(vi)**ជំនួយពីចម្ងាយ៖**អ្នកអាចប្រើបច្ចេកវិទ្យាជំនួយពីចម្ងាយដើម្បីចែករំលែកវេលាប្រើសកម្មមួយដោយមិនទទួលអាជ្ញាបណ្ណបន្ថែមណាមួយសម្រាប់សុហ្វវែរនោះ។ជំនួយពីចម្ងាយ

អនុញ្ញាតឲ្យអ្នកប្រើប្រាស់ម្នាក់ភ្ជាប់ដោយផ្ទាល់ទៅកុំព្យូទ័ររបស់អ្នកប្រើប្រាស់ផ្សេងទៀតជាធម្មតាដើម្បីកែបញ្ហា។

**e.សំណៅចម្លងទុក៖**អ្នកអាចបង្កើតសំណៅចម្លងទុកនៃសុហ្វវែរចំនួនមួយក្នុងគោលបំណងនៃការចម្លងទុកហើយក៏អាចប្រើសំណៅចម្លងទុកនោះដើម្បីផ្ទេរសុហ្វវែរផងដែរបើវាត្រូវបានទទួលជាសុហ្វវែរតែឯងដូចបានពណ៌នាក្នុងប្រការ4ខាងក្រោម។

**3.ភាពឯកជន; ការយល់ព្រមចំពោះការប្រើទិន្នន័យ៖**ភាពឯកជនរបស់អ្នកមានសារៈសំខាន់ណាស់ចំពោះយើង។មុខងារសុហ្វវែរខ្លះផ្ញើឬទទួលព័ត៌មាននៅពេលប្រើមុខងារទាំងនោះ។មុខងារទាំងនេះជាច្រើនអាចត្រូវបានបិទក្នុងអ៊ីនធីហ្វេសអ្នកប្រើប្រាស់ឬអ្នកអាចជ្រើសរើសមិនប្រើពួកវា។ដោយយល់ព្រមទទួលកិច្ចព្រមព្រៀងនេះនិងដោយប្រើសុហ្វវែរនេះអ្នកយល់ព្រមថាMicrosoft អាចប្រមូលប្រើនិងបញ្ចេញព័ត៌មានដូចបានពណ៌នាក្នុងសេចក្ដីថ្លែងពីភាពឯកជនរបស់Microsoft (aka.ms/privacy) និងដូចដែលអាចពណ៌នាក្នុងអ៊ីនធីហ្វេសអ្នកប្រើប្រាស់ដែលពាក់ព័ន្ធជាមួយមុខងារសុហ្វវែរនោះ។

**4.ការផ្ទេរ។**បទបញ្ញត្តិនៃផ្នែកនេះមិនអនុវត្តឡើយបើអ្នកបានទទួលសុហ្វវែរនេះជាអ្នកប្រើប្រាស់ក្នុងប្រទេសអាល្លឺម៉ង់ឬក្នុងប្រទេសណាមួយដែលបានរាយលើវិបសៃនេះ (aka.ms/transfer) ដែលក្នុងករណីនោះការផ្ទេរទាំងឡាយនៃសុហ្វវែរនេះទៅតតីយភាគីនិងសិទ្ធិក្នុងការប្រើវាត្រូវតែអនុលោមតាមច្បាប់ជាធរមាន។

**a.សុហ្វវែរដែលបានដំឡើងជាមុនលើឧបករណ៍៖**បើអ្នកបានទទួលសុហ្វវែរដែលបានដំឡើងជាមុនលើឧបករណ៍ (ហើយបើអ្នកបានដំឡើងថ្នាក់ពីសុហ្វវែរដែលបានដំឡើងជាមុនលើឧបករណ៍មួយផងដែរ) អ្នកអាចផ្ទេរអាជ្ញាបណ្ណដើម្បីប្រើសុហ្វវែរនោះដោយផ្ទាល់ទៅអ្នកប្រើប្រាស់ផ្សេងទៀតតែជាមួយឧបករណ៍ដែលបានទទួលអាជ្ញាបណ្ណប៉ុណ្ណោះ។ការផ្ទេរត្រូវតែរួមបញ្ចូលសុហ្វវែរនេះនិងស្លាកWindows មែនទែនដែលមានសោផលិតផលបើបានផ្ដល់ឲ្យជាមួយឧបករណ៍។មុនពេលផ្ទេរដែលបានទទួលអនុញ្ញាតភាគីមួយទៀតនោះត្រូវតែយល់ព្រមថាកិច្ចព្រមព្រៀងនេះអនុវត្តចំពោះការផ្ទេរនិងការប្រើសុហ្វវែរនេះ។

**b.សុហ្វវែរតែឯង៖**បើអ្នកបានទទួលសុហ្វវែរនេះជាសុហ្វវែរតែឯង (ហើយបើអ្នកដំឡើងថ្នាក់ពីសុហ្វវែរដែលអ្នកបានទទួលជាសុហ្វវែរតែឯង) អ្នកអាចផ្ទេរសុហ្វវែរនេះទៅឧបករណ៍ផ្សេងទៀតដែលជារបស់អ្នក។អ្នកក៏អាចផ្ទេរសុហ្វវែរនេះទៅឧបករណ៍ដែលជារបស់នរណាម្នាក់ផ្សេងទៀតដែរបើ (i) អ្នកគឺជាអ្នកប្រើប្រាស់ដែលបានទទួលអាជ្ញាបណ្ណដំបូងនៃសុហ្វវែរនោះនិង (ii) អ្នកប្រើប្រាស់ថ្មីនោះយល់ព្រមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។អ្នកអាចប្រើសំណៅចម្លងទុកដែលយើងអនុញ្ញាតឲ្យអ្នកបង្កើតឬមេឌៀដែលសុហ្វវែរអមមកជាមួយដើម្បីផ្ទេរសុហ្វវែរ។គ្រប់ពេលដែលអ្នកផ្ទេរសុហ្វវែរទៅឧបករណ៍ថ្មីអ្នកត្រូវតែលុបសុហ្វវែរនោះពីឧបករណ៍ពីមុន។អ្នកមិនអាចផ្ទេរសុហ្វវែរនេះដើម្បីចែករំលែកអាជ្ញាបណ្ណរវាងឧបករណ៍នានាឡើយ។

**5.សុហ្វវែរនិងការបើកដំណើរការដែលទទួលសិទ្ធិ៖**អ្នកទទួលសិទ្ធិក្នុងការប្រើសុហ្វវែរនេះតែក្នុងករណីដែលអ្នកបានទទួលអាជ្ញាបណ្ណសមស្របហើយសុហ្វវែរនេះត្រូវបានបើកដំណើរការសមស្របជាមួយសោផលិតផលមែនទែនឬតាមវិធីដែលទទួលសិទ្ធិផ្សេងទៀតប៉ុណ្ណោះ។នៅពេលអ្នកភ្ជាប់ទៅ

អ៊ីនធឺណិតខណៈពេលប្រើសុហ្វវែរនេះនោះសុហ្វវែរនេះនឹងទាក់ទងMicrosoft ឬសម្ពន្ធរបស់ខ្លួនដោយស្វ័យប្រវត្តិដើម្បីបើកដំណើរការវាលើឧបករណ៍ជាក់លាក់មួយ។អ្នកក៏អាចបើកដំណើរការសុហ្វវែរនេះដោយដៃតាមអ៊ីនធឺណិតឬទូរសព្ទផងដែរ។ក្នុងករណីនេះការបញ្ជូនព័ត៌មានមួយចំនួននឹងកើតឡើងហើយអាចមានការគិតថ្លៃអ៊ីនធឺណិតទូរសព្ទនិងសេវាSMS។ក្នុងអំឡុងពេលបើកដំណើរការ (ឬការបើកដំណើរការឡើងវិញដែលអាចកើតឡើងដោយការផ្លាស់ប្តូរសមាសភាពរបស់ឧបករណ៍អ្នក) សុហ្វវែរនេះអាចដឹងថាវត្ថុបង្ហាញដែលបានដំឡើងនៃសុហ្វវែរនោះគឺក្លែងក្លាយ, មិនបានទទួលអាជ្ញាបណ្ណត្រឹមត្រូវឬក៏រួមបញ្ចូលការផ្លាស់ប្តូរដោយគ្មានការអនុញ្ញាត។បើការបើកដំណើរការបរាជ័យនោះសុហ្វវែរនឹងប៉ុនប៉ងជួសជុលដោយខ្លួនវាតាមរយៈការជំនួសសុហ្វវែរMicrosoft ដែលក្លែងក្លាយនោះដោយសុហ្វវែរMicrosoft មែនទែន។អ្នកក៏អាចទទួលការរំឭកឲ្យទទួលអាជ្ញាបណ្ណសមស្របសម្រាប់សុហ្វវែរនោះដែរ។ការបើកដំណើរការដោយជោគជ័យមិនបញ្ជាក់ថាសុហ្វវែរនេះជារបស់មែនទែនឬបានផ្តល់អាជ្ញាបណ្ណត្រឹមត្រូវឡើយ។អ្នកមិនត្រូវជៀសឬរាំងការបើកដំណើរការឡើយ។ដើម្បីជួយកំណត់ថាតើសុហ្វវែររបស់អ្នកសុទ្ធទេនិងថាតើអ្នកទទួលអាជ្ញាបណ្ណសមស្របទេសូមមើល (aka.ms/genuine)។ បច្ចុប្បន្នភាពការគាំទ្រនិងសេវាផ្សេងទៀតមួយចំនួនអាចត្រូវបានផ្តល់ជូនអ្នកប្រើប្រាស់ដែលមានសុហ្វវែរMicrosoft មែនទែនប៉ុណ្ណោះ។

**6.បច្ចុប្បន្នភាព៖**សុហ្វវែរនឹងពិនិត្យតាមពេលរកបច្ចុប្បន្នភាពនៃប្រព័ន្ធនិងកម្មវិធីហើយទាញយកនិងដំឡើងពួកវាសម្រាប់អ្នក។អ្នកអាចទទួលបច្ចុប្បន្នភាពតែពីMicrosoft ឬប្រភពដែលទទួលសិទ្ធិប៉ុណ្ណោះហើយMicrosoft អាចត្រូវការធ្វើបច្ចុប្បន្នភាពប្រព័ន្ធរបស់អ្នកដើម្បីផ្តល់ជូនអ្នកនូវបច្ចុប្បន្នភាពទាំងនោះ។ដោយយល់ព្រមទទួលកិច្ចព្រមព្រៀងនេះអ្នកយល់ព្រមទទួលប្រភេទនៃបច្ចុប្បន្នភាពដោយស្វ័យប្រវត្តិទាំងនេះដោយគ្មានសេចក្តីជូនដំណឹងបន្ថែមទៀត។

**7.សិទ្ធិនៃការទម្លាក់ថ្នាក់៖**បើអ្នកបានទទួលឧបករណ៍ពីឧស្សាហករឬអ្នកដំឡើងជាមួយកំណែProfessional នៃWindows ដែលបានដំឡើងជាមុនលើវាអ្នកអាចប្រើកំណែWindows 8.1 Pro ឬWindows 7 Professional ឲ្យតែMicrosoft នៅផ្តល់ការគាំទ្រសម្រាប់កំណែមុននោះដូចបានចែងក្នុង (aka.ms/windowslifecycle)។កិច្ចព្រមព្រៀងនេះអនុវត្តចំពោះការប្រើកំណែមុនរបស់អ្នក។បើកំណែមុនរួមមានសមាសភាគផ្សេងលក្ខខណ្ឌទាំងឡាយសម្រាប់សមាសភាគទាំងនោះនៅក្នុងកិច្ចព្រមព្រៀងដែលអមមកជាមួយកំណែមុនអនុវត្តចំពោះការប្រើរបស់អ្នកលើសមាសភាពដូចនោះ។ទាំងឧស្សាហករឬអ្នកដំឡើងឬក៏Microsoft មិនត្រូវមានកាតព្វកិច្ចផ្គត់ផ្គង់កំណែមុនដល់អ្នកឡើយ។អ្នកត្រូវតែទទួលកំណែមុននោះដាច់ដោយឡែកដែលអ្នកអាចត្រូវបានគិតថ្លៃ។នៅគ្រប់ពេលអ្នកអាចជំនួសកំណែមុនដោយកំណែដែលអ្នកបានទទួលមុនដំបូង។

**8.កំហិតភូមិសាស្ត្រនិងការនាំចេញ៖**បើសុហ្វវែររបស់អ្នកត្រូវបានកំហិតសម្រាប់ការប្រើក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយនោះអ្នកអាចបើកដំណើរការសុហ្វវែរនោះតែក្នុងតំបន់នោះប៉ុណ្ណោះ។អ្នកត្រូវតែអនុលោមផងដែរតាមច្បាប់និងបញ្ញត្តិកម្មក្នុងស្រុកនិងអន្តរជាតិទាំងអស់ស្តីពីការនាំចេញដែលអនុវត្តចំពោះសុហ្វវែរនេះដែលរួមបញ្ចូលកំហិតលើទិសដៅអ្នកប្រើប្រាស់ចុងក្រោយនិងការប្រើប្រាស់ចុងក្រោយ។សម្រាប់ព័ត៌មានបន្ថែមអំពីកំហិតភូមិសាស្ត្រនិងការនាំចេញសូមមើល (aka.ms/georestrict) និង (aka.ms/exporting)។

**9.ការគាំទ្រនិងនីតិវិធីនៃការសងប្រាក់វិញ៖**

**a.សម្រាប់សុហ្វវែរដែលបានដំឡើងជាមុនលើឧបករណ៍៖**សម្រាប់សុហ្វវែរនេះជាទូទៅសូមទាក់ទងឧស្សាហករឧបករណ៍ឬអ្នកដំឡើងដើម្បីទទួលជម្រើសគាំទ្រ។យោងទៅលេខគាំទ្រដែលអមមកជាមួយសុហ្វវែរនេះ។សម្រាប់បច្ចុប្បន្នភាពនិងការបំពេញបន្ថែមដែលបានទទួលដោយផ្ទាល់ពីMicrosoft នោះMicrosoft អាចផ្តល់សេវាគាំទ្រមានកម្រិតសម្រាប់សុហ្វវែរដែលមានអាជ្ញាបណ្ណត្រឹមត្រូវដូចបានពណ៌នានៅ (aka.ms/mssupport)។បើអ្នកកំពុងស្វែងរកការសងប្រាក់វិញសូមទាក់ទងឧស្សាហករឬអ្នកដំឡើងដើម្បីបញ្ជាក់អំពីគោលការណ៍សងប្រាក់វិញរបស់គេ។អ្នកត្រូវតែអនុលោមតាមគោលការណ៍ទាំងនោះដែលអាចតម្រូវឲ្យអ្នកត្រឡប់សុហ្វវែរជាមួយឧបករណ៍ទាំងមូលដែលបានដំឡើងសុហ្វវែរក្នុងនោះដើម្បីទទួលការសងប្រាក់វិញ។

**b.សម្រាប់សុហ្វវែរដែលបានទទួលពីអ្នកលក់រាយ៖**Microsoft ផ្តល់សេវាគាំទ្រមានកម្រិតសម្រាប់សុហ្វវែរដែលបានទទួលអាជ្ញាបណ្ណត្រឹមត្រូវដូចបានពណ៌នានៅ (aka.ms/mssupport)។បើអ្នកបានទិញសុហ្វវែរនេះពីអ្នកលក់រាយហើយកំពុងស្វែងរកការសងប្រាក់វិញហើយអ្នកមិនអាចទទួលនៅកន្លែងដែលអ្នកបានទទួលសុហ្វវែរសូមទាក់ទងMicrosoft សម្រាប់ព័ត៌មានអំពីគោលការណ៍សងប្រាក់វិញរបស់Microsoft។មើល (aka.ms/msoffices) ឬនៅអាមេរិកខាងជើងសូមហៅ (800) MICROSOFT ឬមើល (aka.ms/nareturns)។

**10.មជ្ឈត្តវិនិច្ឆ័យជាប់កាតព្វកិច្ចនិងការលះបង់ចំណាត់ការជាក្រុមបើអ្នករស់នៅក្នុង (ឬក៏បើកន្លែងគោលនៃអាជីវកម្មរបស់អ្នកស្ថិតក្នុង) សហរដ្ឋអាមេរិក៖**

យើងសង្ឃឹមថាយើងនឹងមិនមានទំនាស់ណាមួយឡើយប៉ុន្តែបើយើងមានអ្នកនិងយើងយល់ព្រមជាមួយគ្នាព្យាយាមដោះស្រាយទំនាស់នោះក្រៅផ្លូវការក្នុងពេល 60 ថ្ងៃ។បើយើងមិនអាចធ្វើទេអ្នកនិងយើងយល់ព្រមចំពោះ**មជ្ឈត្តវិនិច្ឆ័យជាបុគ្គលជាប់កាតព្វកិច្ចនៅចំពោះមុខសមាគមមជ្ឈត្តវិនិច្ឆ័យអាមេរិកាំង (“AAA”) ក្រោមច្បាប់មជ្ឈត្តវិនិច្ឆ័យរបស់សហព័ន្ធ (“FAA”) ហើយនឹងមិនប្តឹងនៅក្នុងតុលាការនៅចំពោះមុខចៅក្រមឬគណៈវិនិច្ឆ័យឡើយ**។ជំនួសនេះមជ្ឈត្តករអព្យាក្រឹតនឹងធ្វើសេចក្តីសម្រេចចិត្តហើយសេចក្តីសម្រេចរបស់មជ្ឈត្តករនឹងជាសេចក្តីសម្រេចចុងក្រោយលើកលែងតែសិទ្ធិប្តឹងឧទ្ធរណ៍មានកម្រិតក្រោមច្បាប់FAA ប៉ុណ្ណោះ។**បណ្តឹងតាមផ្លូវច្បាប់នៃចំណាត់ការជាក្រុម, មជ្ឈត្តវិនិច្ឆ័យជាក្រុម, ចំណាត់ការរបស់អគ្គមេធាវីឯកជននិងនីតិវិធីដទៃផ្សេងទៀតដែលនរណាម្នាក់ចាត់ការក្នុងនាមជាអ្នកតំណាងមិនទទួលការអនុញ្ញាតឡើយ។ហើយបណ្តឹងជាបុគ្គលរួមគ្នាដោយគ្មានការយល់ព្រមពីភាគីទាំងអស់ក៏មិនទទួលការអនុញ្ញាតដែរ។**“យើង” និង“របស់យើង” រួមបញ្ចូលMicrosoft, ឧស្សាហករឧបករណ៍និងអ្នកដំឡើងសុហ្វវែរ។

**a.ទំនាស់ដែលត្រូវបានគ្របដណ្តប់—គ្រប់យ៉ាងលើកលែងIP៖**ពាក្យ“ទំនាស់” មានលក្ខណៈទូលំទូលាយតាមដែលអាចឲ្យអត្ថន័យ។វារួមបញ្ចូលបណ្តឹងនានាឬវិវាទរវាងអ្នកនិងឧស្សាហករឬអ្នកដំឡើងឬក៏អ្នកនិងMicrosoft ពាក់ព័ន្ធនឹងសុហ្វវែរតម្លៃរបស់វាឬកិច្ចព្រមព្រៀងនេះក្រោមទ្រឹស្តីច្បាប់ទាំងឡាយរួមទាំងកិច្ចសន្យាការធានាកំហុសរដ្ឋប្បវេណីឬបញ្ញត្តិកម្ម**លើកលែងទំនាស់ពាក់ព័ន្ធនឹងការអនុវត្តឬសុពលភាពនៃកម្មសិទ្ធិបញ្ញារបស់អ្នករបស់អ្នកផ្តល់អាជ្ញាបណ្ណឲ្យអ្នករបស់យើងឬរបស់អ្នកផ្តល់អាជ្ញាបណ្ណឲ្យយើង។**

**b.ផ្ញើសេចក្តីជូនដំណឹងពីទំនាស់ជាមុនសិន៖**បើអ្នកមានទំនាស់ហើយអ្នកតំណាងសេវាអតិថិជនរបស់យើងមិនអាចដោះស្រាយវាបានទេសូមផ្ញើសេចក្តីជូនដំណឹងពីទំនាស់តាមសំបុត្រប្រៃសណីយ៍សហរដ្ឋអាមេរិកទៅឧស្សាហករឬអ្នកដំឡើងជូនចំពោះផ្នែកច្បាប់។បើទំនាស់របស់អ្នកគឺជាមួយMicrosoft សូមផ្ញើវាតាមសំបុត្រប្រៃសណីយ៍ទៅMicrosoft Corporation, ATTN: LCA ARBITRATION, One Microsoft Way, Redmond, WA 98052-6399។ប្រាប់យើងពីឈ្មោះរបស់អ្នកអាសយដ្ឋានរបៀបទាក់ទងអ្នកអ្វីជាបញ្ហានិងអ្វីដែលអ្នកចង់បាន។ទម្រង់បែបបទមាននៅ (aka.ms/disputeform)។យើងនឹងធ្វើដូចគ្នាបើយើងមានទំនាស់ជាមួយអ្នក។បើទំនាស់នោះមិនត្រូវបានដោះស្រាយបន្ទាប់ពីពេល60ថ្ងៃអ្នកឬយើងអាចចាប់ផ្តើមមជ្ឈត្តវិនិច្ឆ័យ។

**c.ជម្រើសនៅតុលាការបណ្តឹងតូចតាច៖**ជំនួសឲ្យការផ្ញើសេចក្តីជូនដំណឹងពីទំនាស់តាមសំបុត្រហើយបើអ្នកបំពេញតាមតម្រូវការរបស់តុលាការអ្នកអាចប្តឹងយើងក្នុងតុលាការបណ្តឹងតូចតាចក្នុងខោនធីទីលំនៅរបស់អ្នក (ឬបើជាអាជីវកម្មគឺកន្លែងគោលនៃអាជីវកម្មរបស់អ្នក) ឬកន្លែងគោលនៃអាជីវកម្មរបស់យើង–King County, Washington USA បើទំនាស់របស់អ្នកគឺជាមួយMicrosoft។យើងសង្ឃឹមថាអ្នកនឹងផ្ញើសេចក្តីជូនដំណឹងពីទំនាស់ឬផ្តល់ឲ្យយើងនូវពេល60ថ្ងៃដើម្បីព្យាយាមដោះស្រាយទំនាស់នោះប៉ុន្តែអ្នកមិនចាំបាច់រង់ចាំឡើយបើអ្នកទៅតុលាការបណ្តឹងតូចតាច។

**d.នីតិវិធីមជ្ឈត្តវិនិច្ឆ័យ៖**The AAA នឹងធ្វើមជ្ឈត្តវិនិច្ឆ័យនានាក្រោមវិធានមជ្ឈត្តវិនិច្ឆ័យពាណិជ្ជកម្មរបស់ខ្លួន (ឬបើអ្នកគឺជារូបវន្តបុគ្គលនិងប្រើសុហ្វវែរសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនឬក្នុងគ្រួសារឬក៏បើតម្លៃនៃទំនាស់គឺ$75,000 USD ឬតិចជាងនេះមិនថាអ្នកជារូបវន្តបុគ្គលឬរបៀបដែលអ្នកប្រើសុហ្វវែរឡើយគឺប្រើវិធានមជ្ឈត្តវិនិច្ឆ័យសម្រាប់អ្នកប្រើប្រាស់)។សម្រាប់ព័ត៌មានបន្ថែមសូមមើល (aka.ms/adr) ឬហៅទូរសព្ទទៅលេខ1-800-778-7879។ដើម្បីចាប់ផ្តើមមជ្ឈត្តវិនិច្ឆ័យសូមប្រគល់ទម្រង់បែបបទដែលអាចរកបាននៅ (aka.ms/arbitration) ជូនAAA; ផ្ញើសំណៅចម្លងមួយច្បាប់ទៅឧស្សាហករឬអ្នកដំឡើង (ឬទៅMicrosoft បើទំនាស់របស់អ្នកគឺជាមួយMicrosoft)។ក្នុងទំនាស់ដែលពាក់ព័ន្ធនឹងទឹកប្រាក់$25,000 USD ឬតិចជាងនេះសវនការទាំងឡាយនឹងធ្វើឡើងតាមទូរសព្ទលុះត្រាតែមជ្ឈត្តកររកឃើញបុព្វហេតុល្អក្នុងការបើកសវនការផ្ទាល់មុខជំនួសនោះ។សវនការផ្ទាល់មុខទាំងឡាយនឹងធ្វើឡើងក្នុងខោនធីទីលំនៅរបស់អ្នក (ឬបើជាអាជីវកម្មគឺកន្លែងគោលនៃអាជីវកម្មរបស់អ្នក) ឬកន្លែងគោលនៃអាជីវកម្មរបស់យើង—King County, Washington បើទំនាស់របស់អ្នកគឺជាមួយMicrosoft។អ្នកអាចជ្រើសរើសបាន។មជ្ឈត្តវិនិច្ឆ័យអាចសម្រេចផ្តល់សំណងខូចខាតដូចគ្នាជូនអ្នកជាបុគ្គលដូចដែលតុលាការអាចធ្វើដែរ។មជ្ឈត្តករអាចសម្រេចធ្វើសេចក្តីប្រកាសឬការសម្រាលបង្គាប់តែចំពោះអ្នកជាបុគ្គលប៉ុណ្ណោះដើម្បីបំពេញតាមបណ្តឹងជាបុគ្គលរបស់អ្នក។

**e.ថ្លៃសេវានិងការបង់ប្រាក់មជ្ឈត្តវិនិច្ឆ័យ៖**

(i)**ទំនាស់ពាក់ព័ន្ធនឹងប្រាក់$75,000 USD ឬតិចជាងនេះ៖**ឧស្សាហករឬអ្នកដំឡើង (ឬMicrosoft បើទំនាស់របស់អ្នកគឺជាមួយMicrosoft) នឹងសងថ្លៃសេវាដាក់ឯកសាររបស់អ្នកភ្លាមៗហើយបង់ថ្លៃសេវានិងការចំណាយរបស់AAA និងមជ្ឈត្តករ។បើអ្នកបដិសេធការដោះស្រាយជាលាយលក្ខណ៍អក្សរចុងក្រោយរបស់យើងដែលបានធ្វើមុនពេលចាត់តាំង

មជ្ឈត្តវិនិច្ឆយទំនាស់របស់អ្នកនឹងបន្តទៅមុខដើម្បីទទួលសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆយ (ហៅថា“សេចក្តីសម្រេច” ហើយបើមជ្ឈត្តករសម្រេចផ្តល់ជូនអ្នកលើសពីអ្វីដែលបានផ្តល់ជូនជាលាយលក្ខណ៍អក្សរចុងក្រោយនេះឧស្សាហករឬអ្នកដំឡើង (ឬMicrosoft បើទំនាស់របស់អ្នកគឺជាមួយMicrosoft) នឹងៈ (1) បង់ប្រាក់ច្រើនជាងសេចក្តីសម្រេចនោះឬ$1,000 USD; (2) បង់ថ្លៃសេវាសមហេតុផលរបស់មេធាវីអ្នកបើមាន; និង (3) សងការចំណាយនានា (រួមទាំងថ្លៃសេវានិងសោហ៊ុយរបស់អ្នកឯកទេស) ដែលមេធាវីរបស់អ្នកបន្ថែមសមស្របសម្រាប់ការស៊ើបអង្កេតការរៀបចំនិងតវ៉ាក្តីរបស់អ្នកនៅក្នុងមជ្ឈត្តិវិនិច្ឆយ។មជ្ឈត្តករនឹងសម្រេចពីចំនួនទឹកប្រាក់នោះលុះត្រាតែអ្នកនិងយើងយល់ព្រមលើពួកវា។

(ii)**ទំនាស់ពាក់ព័ន្ធនឹងប្រាក់ច្រើនជាង$75,000 USD៖**វិធានAAA នឹងគ្របដណ្តប់លើការបង់ប្រាក់ថ្លៃសេវាដាក់ឯកសារនិងថ្លៃសេវានិងការចំណាយរបស់AAA និងមជ្ឈត្តិករ។

(iii)**ទំនាស់ពាក់ព័ន្ធនឹងចំនួនទឹកប្រាក់នានា៖**បើអ្នកចាប់ផ្តើមមជ្ឈត្តវិនិច្ឆយយើងនឹងមិនទាមទារមកវិញនូវថ្លៃសេវានិងការចំណាយAAA ឬមជ្ឈត្តករដែលយើងបានបង់ឬក៏ថ្លៃសេវាដាក់បណ្តឹងរបស់អ្នកដែលយើងបានបង់ឡើយលុះត្រាតែមជ្ឈត្តកររកឃើញថាមជ្ឈត្តវិនិច្ឆយនោះមានលក្ខណៈផ្តេសផ្តាសឬបានលើកឡើងក្នុងគោលបំណងមិនសមស្រប។បើយើងចាប់ផ្តើមមជ្ឈត្តវិនិច្ឆយយើងនឹងបង់ថ្លៃដាក់បណ្តឹងទាំងអស់ថ្លៃសេវានិងការចំណាយរបស់AAA និងមជ្ឈត្តករ។យើងនឹងមិនទាមទារថ្លៃសេវានិងការចំណាយរបស់មេធាវីយើងពីអ្នកឡើយនៅក្នុងមជ្ឈត្តវិនិច្ឆយទាំងឡាយ។ថ្លៃសេវានិងការចំណាយមិនត្រូវបានរាប់ក្នុងការសម្រេចថាតើទំនាស់នោះមានចំនួនទឹកប្រាក់ពាក់ព័ន្ធប៉ុន្មានឡើយ។

**f.ត្រូវតែដាក់ឯកសារក្នុងរយៈពេលមួយឆ្នាំ៖**អ្នកនិងយើងត្រូវតែដាក់ពាក្យបណ្តឹងឬវិវាទទាំងឡាយក្នុងតុលាការបណ្តឹងតូចតាចឬមជ្ឈត្តវិនិច្ឆយ (លើកលែងវិវាទពីកម្មសិទ្ធិបញ្ញា) —មើលប្រការ10.a.) ក្នុងរយៈពេលមួយឆ្នាំពីពេលដែលវាអាចដាក់ដំបូង។បើពុំនោះវានឹងត្រូវបានហាមឃាត់ជារៀងរហូត។

**g.ភាពដាច់ពីគ្នា៖**បើការលះបង់ចំណាត់ការជាក្រុមត្រូវបានរកឃើញថាខុសច្បាប់ឬមិនអាចអនុវត្តបានទាំងស្រុងឬចំពោះផ្នែកណាមួយនៃទំនាស់នោះផ្នែកទាំងនោះនឹងមិនត្រូវបានធ្វើមជ្ឈត្តវិនិច្ឆយឡើយប៉ុន្តែនឹងបន្តនៅក្នុងតុលាការដោយផ្នែកដែលនៅសល់នឹងបន្តធ្វើក្នុងមជ្ឈត្តវិនិច្ឆយ។បើបទបញ្ញត្តិដទៃទៀតនៃប្រការ10ត្រូវបានរកឃើញថាខុសច្បាប់ឬមិនអាចអនុវត្តបានបទបញ្ញត្តិនោះនឹងនៅដាច់ដោយឡែកប៉ុន្តែផ្នែកនៅសល់នៃប្រការ10នៅតែអនុវត្តដដែល។

**h.ទំនាស់ជាមួយវិធានAAA៖**កិច្ចព្រមព្រៀងនេះគ្របដណ្តប់ក្នុងករណីដែលវាមានទំនាស់ជាមួយវិធានមជ្ឈត្តវិនិច្ឆយពាណិជ្ជកម្មរបស់AAA ឬវិធានមជ្ឈត្តវិនិច្ឆយអ្នកប្រើប្រាស់។

**i.Microsoft ជាភាគីឬជាតតិយភាគីទទួលផល។**បើMicrosoft គឺជាឧស្សាហករឧបករណ៍ឬបើអ្នកបានទទួលសុហ្វវែរពីអ្នកលក់រាយMicrosoft គឺជាភាគីមួយនៃកិច្ចព្រមព្រៀងនេះ។

បើពុំនោះMicrosoft មិនមែនជាភាគីមួយឡើយប៉ុន្តែជាតតីយភាគីទទួលផលនៃកិច្ចព្រមព្រៀងរបស់អ្នកជាមួយឧស្សាហករឬអ្នកដំឡើងក្នុងការដោះស្រាយទំនាស់តាមការចរចាក្រៅផ្លូវការនិងមជ្ឈត្តកវិនិច្ឆ័យ។

11.**ច្បាប់គ្រប់ដណ្តប់៖**ច្បាប់របស់រដ្ឋឬប្រទេសដែលអ្នករស់នៅ (ឬបើជាអាជីវកម្មគឺកន្លែងគោលដែលអាជីវកម្មរបស់អ្នកស្ថិតនៅ) គ្រប់ដណ្តប់លើបណ្តឹងនិងវិវាទទាំងអស់ពាក់ព័ន្ធនឹងសុហ្វវែរតម្លៃរបស់វាកិច្ចព្រមព្រៀងនេះរួមទាំងបណ្តឹងនៃការបំពានលើកិច្ចសន្យានិងបណ្តឹងក្រោមច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ច្បាប់ស្តីពីការប្រកួតប្រជែងមិនស្មោះត្រង់ច្បាប់ស្តីពីការធានាបង្កប់ន័យសម្រាប់ការកែលម្អភាពអយុត្តិធម៌និងកំហុសរដ្ឋប្បវេណីដោយមិនគិតពីវិវាទនៃគោលការណ៍ច្បាប់។ក្នុងសហរដ្ឋអាមេរិកFAA គ្រប់ដណ្តប់លើបទបញ្ញត្តិទាំងអស់ដែលពាក់ព័ន្ធនឹងមជ្ឈត្តកវិនិច្ឆ័យ។

12.**សិទ្ធិរបស់អ្នកប្រើប្រាស់, ភាពខុសគ្នាតាមតំបន់៖**កិច្ចព្រមព្រៀងនេះពណ៌នាអំពីសិទ្ធិស្របច្បាប់ជាក់លាក់មួយចំនួន។អ្នកអាចមានសិទ្ធិដទៃទៀតរួមទាំងសិទ្ធិជាអ្នកប្រើប្រាស់ក្រោមច្បាប់នៃរដ្ឋឬប្រទេសរបស់អ្នក។អ្នកក៏អាចមានសិទ្ធិពាក់ព័ន្ធនឹងភាគីដែលផ្តល់សុហ្វវែរនេះដល់អ្នកផងដែរ។កិច្ចព្រមព្រៀងនេះមិនផ្លាស់ប្តូរសិទ្ធិដទៃទៀតទាំងនោះទេបើច្បាប់នៃរដ្ឋឬប្រទេសរបស់អ្នកនោះមិនអនុញ្ញាតឲ្យវាធ្វើដូច្នេះ។ឧទាហរណ៍បើអ្នកបានទទួលសុហ្វវែរនេះក្នុងតំបន់ណាមួយខាងក្រោមឬច្បាប់ចាំបាច់របស់ប្រទេសត្រូវអនុវត្តនោះបទបញ្ញត្តិខាងក្រោមនឹងអនុវត្តចំពោះអ្នក៖

a.**អូស្ត្រាលី៖**ការយោងថា"ការធានាមានកម្រិត" គឺជាការយោងទៅការធានាដែលបានបញ្ជាក់ដែលMicrosoft ឬឧស្សាហករឬក៏អ្នកដំឡើងបានផ្តល់ឲ្យ។ការធានានេះត្រូវបានផ្តល់ជូនបន្ថែមលើសិទ្ធិនិងការកែខៃផ្សេងទៀតដែលអ្នកអាចមានក្រោមច្បាប់រួមទាំងសិទ្ធិរបស់អ្នកនិងការកែខៃនានាស្របតាមការធានាតាមឧបញ្ញត្តិក្រោមច្បាប់ស្តីពីអ្នកប្រើប្រាស់អូស្ត្រាលី។

ក្នុងផ្នែកនេះ"ទំនិញ" សំដៅលើសុហ្វវែរដែលMicrosoft ឬឧស្សាហករឬអ្នកដំឡើងផ្តល់ការធានាដែលបានបញ្ជាក់។ទំនិញរបស់យើងអមមកជាមួយការធានាដែលមិនអាចដកចេញក្រោមច្បាប់ស្តីពីអ្នកប្រើប្រាស់អូស្ត្រាលី។អ្នកមានសិទ្ធិទទួលរបស់ផ្លាស់ប្តូរថ្មីឬសំណងប្រាក់វិញសម្រាប់ការខូចធំៗព្រមទាំងសំណងសម្រាប់ការខាតបង់ឬការខូចខាតដែលអាចប្រមើលឃើញសមហេតុផល។អ្នកក៏មានសិទ្ធិឲ្យគេជួសជុលទំនិញទាំងនោះឬផ្លាស់ថ្មីផងដែរបើទំនិញនោះមិនអាចមានគុណភាពដែលអាចទទួលយកបានហើយការខូចនោះមិនគិតថាជាការខូចធំៗ។

b.**កាណាដា៖**អ្នកអាចបញ្ឈប់ការទទួលបច្ចុប្បន្នភាពលើឧបករណ៍របស់អ្នកដោយបិទការចូលប្រើអ៊ីនធឺណិត។បើនិងនៅពេលអ្នកភ្ជាប់ឡើងវិញទៅអ៊ីនធឺណិតសុហ្វវែរនឹងចាប់ផ្តើមបន្តការពិនិត្យមើលនិងការដំឡើងបច្ចុប្បន្នភាព។

c.**សហគមន៍អឺរ៉ុប៖**កំហិតនៃការប្រើប្រាស់សម្រាប់ការសិក្សានៅក្នុងប្រការ13.d(i) ខាងក្រោមមិនអនុវត្តក្នុងដែនដីយុត្តាធិការដែលបានរាយលើវិបសៃនេះទេ៖ (aka.ms/academicuse)។

d.**អាល្លឺម៉ង់និងអូទ្រីស៖**

(i)**ការធានា៖**សុហ្វវែរដែលបានទទួលអាជ្ញាបណ្ណត្រឹមត្រូវនឹងប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនដូចបានពណ៌នាក្នុងឯកសារMicrosoft ទាំងឡាយដែលអមមកជាមួយសុហ្វវែរ។ទោះជាយ៉ាងនេះក្តីឧស្សាហករឬអ្នកដំឡើងនិងMicrosoft មិនផ្តល់ការធានាតាមកិច្ចសន្យាពាក់ព័ន្ធនឹងសុហ្វវែរដែលបានទទួលអាជ្ញាបណ្ណឡើយ។

(ii)**ដែនកំណត់នៃការទទួលខុសត្រូវ៖**ក្នុងករណីប្រព្រឹត្តដោយចេតនាការធ្វេសប្រហែសទាំងស្រុងបណ្តឹងផ្អែកលើច្បាប់ស្តីពីការទទួលខុសត្រូវលើផលិតផលព្រមទាំងក្នុងករណីមានមរណភាពឬរបួសដល់ខ្លួនឬរាងកាយឧស្សាហករឬអ្នកដំឡើងឬMicrosoft ត្រូវទទួលខុសត្រូវស្របតាមច្បាប់ជាធរមាន។

ស្ថិតក្រោមការកាត់ក្តីពីមុនឧស្សាហករឬអ្នកដំឡើងឬក៏Microsoft នឹងទទួលខុសត្រូវចំពោះការធ្វេសប្រហែសតិចតួចតែក្នុងករណីដែលឧស្សាហករឬអ្នកដំឡើងឬក៏Microsoft កំពុងបំពានលើកាតព្វកិច្ចតាមកិច្ចសន្យាជាសារវន្តនោះកំពុងបំពានលើការបំពេញកាតព្វកិច្ចត្រឹមត្រូវលើកិច្ចព្រមព្រៀងនេះមានការបំពានដែលអាចបង្កអន្តរាយដល់គោលបំណងនៃកិច្ចព្រមព្រៀងនេះនិងអនុលោមភាពដែលភាគីអាចទុកចិត្តបាន (ដែលហៅថា"កាតព្វកិច្ចសំខាន់")។ការធ្វេសប្រហែសតិចតួចក្នុងករណីផ្សេងទៀតឧស្សាហករឬអ្នកដំឡើងឬក៏Microsoft នឹងមិនទទួលខុសត្រូវចំពោះការធ្វេសប្រហែសតិចតួចនោះឡើយ។

**e.តំបន់ផ្សេងទៀត។**មើល (aka.ms/variations) សម្រាប់បញ្ជីបច្ចុប្បន្ននៃភាពខុសគ្នាតាមតំបន់។

## 13.សេចក្តីជូនដំណឹងបន្ថែម៖

**a.បណ្តាញទិន្នន័យនិងការប្រើប្រាស់អ៊ីនធឺណិត៖**មុខងារខ្លះនៃសុហ្វវែរនិងសេវាដែលចូលប្រើតាមសុហ្វវែរនេះអាចតម្រូវឲ្យឧបករណ៍របស់អ្នកចូលប្រើអ៊ីនធឺណិត។ការចូលប្រើនិងការប្រើប្រាស់របស់អ្នក (រួមទាំងការគិតថ្លៃ) អាចស្ថិតក្រោមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទូរសព្ទចល័តឬអ្នកផ្តល់សេវាអ៊ីនធឺណិតឲ្យអ្នក។មុខងារមួយចំនួននៃសុហ្វវែរអាចជួយអ្នកឲ្យចូលប្រើអ៊ីនធឺណិតកាន់តែមានប្រសិទ្ធភាពប៉ុន្តែការគណនាការប្រើប្រាស់របស់សុហ្វវែរអាចខុសពីការវាស់វែងរបស់អ្នកផ្តល់សេវាឲ្យអ្នក។ជានិច្ចកាលអ្នកត្រូវទទួលខុសត្រូវចំពោះ (i) ការដឹងនិងការអនុលោមតាមលក្ខខណ្ឌនៃគម្រោងនិងកិច្ចព្រមព្រៀងផ្ទាល់ខ្លួនរបស់អ្នកនិង (ii) បញ្ហាទាំងឡាយដែលកើតឡើងពីការប្រើឬការចូលប្រើបណ្តាញរួមទាំងបណ្តាញសាធារណៈ/បណ្តាញបើក។អ្នកអាចប្រើសុហ្វវែរដើម្បីភ្ជាប់បណ្តាញនិងដើម្បីចែករំលែកព័ត៌មាននៃការចូលប្រើបណ្តាញទាំងនោះតែក្នុងករណីដែលអ្នកមានការអនុញ្ញាតក្នុងការធ្វើដូច្នោះប៉ុណ្ណោះ។

**b.ស្តង់ដារូបH.264/AVC និងMPEG-4និងស្តង់ដាវីដេអូVC-1៖**សុហ្វវែរនេះរួមបញ្ចូលបច្ចេកវិទ្យាH.264/MPEG-4 AVC និង/ឬVC-1។MPEG LA, L.L.C. តម្រូវឲ្យមានសេចក្តីជូនដំណឹងនេះ៖

ផលិតផលនេះបានទទួលអាជ្ញាបណ្ណក្រោមអាជ្ញាបណ្ណកញ្ចប់នៃប្រកាសនីយបត្រគក្កកម្មរូបAVC, VC-1 និងMPEG-4 ផ្នែក 2 សម្រាប់ការប្រើផ្ទាល់ខ្លួននិងការប្រើមិនមែនជំនួញរបស់អ្នកប្រើប្រាស់ដើម្បី (i) អ៊ិនកូដវីដេអូអនុលោមតាមបទដ្ឋានខាងលើ ("បទដ្ឋានវីដេអូ") និង/ឬ (ii) ឌិកូដវីដេអូAVC, VC-1 និងMPEG-4 ផ្នែក 2 ដែលត្រូវបានអ៊ិនកូដដោយអ្នកប្រើប្រាស់ដែលមានសកម្មភាពផ្ទាល់ខ្លួននិងមិនមែនជំនួញនិង/ឬត្រូវបានទទួលពីក្រុមហ៊ុនផ្តល់វីដេអូដែលបានផ្តល់អាជ្ញាបណ្ណឲ្យផ្តល់វីដេអូនោះ។គ្មានអាជ្ញាបណ្ណណាមួយត្រូវបានផ្តល់ឲ្យឬត្រូវបានបង្កប់ន័យសម្រាប់ការប្រើដទៃផ្សេងទៀតឡើយ។ព័ត៌មានបន្ថែមទៀតអាចទទួលបានពីMPEG LA, L.L.C.។មើល (AKA.MS/MPEGLA)។

**c.ការការពារសុហ្វវែរព្យាបាទ។**Microsoft យកចិត្តទុកដាក់អំពីការការពារឧបករណ៍របស់អ្នកពីសុហ្វវែរព្យាបាទ។សុហ្វវែរនឹងបើកការការពារសុហ្វវែរព្យាបាទបើការការពារផ្សេងទៀតមិនត្រូវបានដំឡើងឬបានផុតកំណត់។ដើម្បីធ្វើដូច្នេះសុហ្វវែរប្រឆាំងសុហ្វវែរព្យាបាទនឹងត្រូវបានបិទហើយអាចត្រូវបានលុបចោល។

**d.កំណែដែលមានសិទ្ធិមានកម្រិត៖**បើកំណែសុហ្វវែរដែលអ្នកបានទទួលត្រូវបានសម្គាល់ឬក៏មានបំណងឲ្យប្រើជាពិសេសឬមានកម្រិតនោះអ្នកអាចប្រើវាដូចបានបញ្ជាក់ប៉ុណ្ណោះ។អ្នកមិនត្រូវប្រើកំណែនៃសុហ្វវែរនោះសម្រាប់សកម្មភាពពាណិជ្ជកម្មមិនមែនស្វែងរកប្រាក់ចំណេញឬបង្កើតចំណូលឡើយ។

(i)**ការសិក្សា៖**សម្រាប់ការប្រើប្រាស់លក្ខណៈសិក្សាអ្នកត្រូវតែជាសិស្សមហាវិទ្យាល័យឬបុគ្គលិករបស់ស្ថាប័នអប់រំនៅពេលទិញ។

(ii)**ការវាយតម្លៃ៖**សម្រាប់ការប្រើប្រាស់លក្ខណៈវាយតម្លៃ (ឬតេស្តឬការបង្ហាញ) អ្នកមិនត្រូវលក់សុហ្វវែរប្រើវាក្នុងបរិស្ថានប្រតិបត្តិការផ្ទាល់ឬប្រើវាបន្ទាប់ពីអំឡុងពេលវាយតម្លៃឡើយ។មិនថាមានឧបញ្ញត្តិអ្វីមួយផ្ទុយគ្នាក្នុងកិច្ចព្រមព្រៀងនេះឡើយ**សុហ្វវែរវាយតម្លៃនេះត្រូវបានផ្តល់ជូន"ដូចដែលមាន" ហើយគ្មានការធានាអ្វីឡើយទោះបង្កប់ន័យឬបញ្ជាក់ន័យក្តី (រួមទាំងការធានាមានកម្រិត) នឹងអនុវត្តចំពោះកំណែទាំងនេះ។**

(iii)**NFR៖**អ្នកមិនត្រូវលក់សុហ្វវែរដែលបានសម្គាល់ថា"NFR" ឬ"Not for Resale" (មិនមែនសម្រាប់លក់បន្ត) ឡើយ។

(iv)**សុហ្វវែរមើលមុន៖**អ្នកអាចជ្រើសរើសប្រើសុហ្វវែរមើលមុនព័ត៌មានផ្ទៃក្នុងប៉េតាឬកំណែចេញមុនផ្សេងទៀតនៃសុហ្វវែរនេះ ("សុហ្វវែរមើលមុន") ដែលMicrosoft អាចបង្កើតឲ្យមាន។អ្នកអាចប្រើសុហ្វវែរមើលមុនត្រឹមកាលបរិច្ឆេទផុតកំណត់នៃសុហ្វវែរនេះប៉ុណ្ណោះហើយឲ្យតែអ្នកអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះទាំងអស់។សុហ្វវែរមើលមុនគឺសម្រាប់ពិសោធហើយអាចខុសគ្នាច្រើនពីកំណែចេញលក់ផ្លូវការ។មិនថាមានឧបញ្ញត្តិអ្វីមួយផ្ទុយគ្នាក្នុងកិច្ចព្រមព្រៀងនេះឡើយ**សុហ្វវែរមើលមុននេះត្រូវបានផ្តល់ជូន"ដូចដែលមាន" ហើយគ្មានការធានាអ្វីឡើយទោះបង្កប់ន័យឬបញ្ជាក់ន័យក្តី (រួមទាំងការធានាមានកម្រិត) នឹងអនុវត្តចំពោះកំណែទាំងនេះ។ដោយដំឡើងសុហ្វវែរមើលមុនលើឧបករណ៍**

**របស់អ្នកអ្នកអាចបាត់បង់ឬធ្វើឲ្យប៉ះពាល់ដល់ការធានានៃឧបករណ៍របស់អ្នកហើយប្រហែលជាមិនទទួលសិទ្ធិគាំទ្រពីឧស្សាហករនៃឧបករណ៍របស់អ្នកឬប្រតិបត្តិករបណ្ដាញឡើយបើមាន**។Microsoft មិនទទួលខុសត្រូវចំពោះការខូចខាតទាំងឡាយដែលកើតឡើងចំពោះអ្នកឡើយ។Microsoft ប្រហែលជាមិនផ្ដល់សេវាគាំទ្រសម្រាប់សុហ្វវែរមើលមុនឡើយ។ បើអ្នកផ្ដល់មតិសំណើឬមតិតបផ្សេងទៀតជូនMicrosoft អំពីសុហ្វវែរមើលមុននេះ ("ការប្រគល់") អ្នកផ្ដល់ជូនMicrosoft និងដៃគូរបស់ខ្លួននូវសិទ្ធិក្នុងការប្រើការប្រគល់នោះតាមវិធីនានានិងក្នុងគោលបំណងនានា។

**14.កិច្ចព្រមព្រៀងទាំងមូល៖**កិច្ចព្រមព្រៀងនេះ (រួមបញ្ចូលជាមួយលក្ខខណ្ឌអាជ្ញាបណ្ណលើក្រដាសដែលបានបោះពុម្ពឬលក្ខខណ្ឌផ្សេងទៀតដែលអមកមកជាមួយកម្មវិធីបំពេញបន្ថែមបច្ចុប្បន្នភាពនិងសេវាដែលឧស្សាហករឬអ្នកដំឡើងឬក៏Microsoft ផ្ដល់ឲ្យនិងដែលអ្នកប្រើ) ព្រមទាំងលក្ខខណ្ឌដែលមានក្នុងតំណរិបដែលបានរាយក្នុងកិច្ចព្រមព្រៀងនេះគឺជាកិច្ចព្រមព្រៀងទាំងមូលសម្រាប់សុហ្វវែរនោះនិងកម្មវិធីបំពេញបន្ថែមបច្ចុប្បន្នភាពនិងសេវាទាំងអស់នោះ (លុះត្រាតែឧស្សាហករឬអ្នកដំឡើងឬក៏Microsoft ផ្ដល់លក្ខខណ្ឌផ្សេងទៀតជាមួយកម្មវិធីបំពេញបន្ថែមបច្ចុប្បន្នភាពនិងសេវាទាំងអស់នោះ)។អ្នកអាចត្រួតពិនិត្យកិច្ចព្រមព្រៀងនេះបន្ទាប់ពីសុហ្វវែររបស់អ្នកដំណើរការដោយចូលទៅ (aka.ms/useterms) ឬក៏ចូលទៅការកំណត់ - ប្រព័ន្ធ - អំពីនៅក្នុងសុហ្វវែរនេះ។អ្នកក៏អាចត្រួតពិនិត្យមើលលក្ខខណ្ឌទាំងនោះតាមតំណណាមួយក្នុងកិច្ចព្រមព្រៀងនេះផងដែរដោយវាយបញ្ចូលURLs ទៅក្នុងរបារអាសយដ្ឋានប្រោវសឺហើយអ្នកយល់ព្រមធ្វើដូច្នេះ។អ្នកយល់ព្រមថាអ្នកនឹងអានលក្ខខណ្ឌទាំងនេះមុនពេលប្រើសុហ្វវែរឬសេវារួមទាំងលក្ខខណ្ឌដែលបានតទាំងឡាយ។អ្នកដឹងថាដោយប្រើសុហ្វវែរនិងសេវាទាំងនេះអ្នកផ្ដល់សច្ចាបណ្ណដល់កិច្ចព្រមព្រៀងនេះនិងលក្ខខណ្ឌដែលបានតភ្ជាប់។យើងក៏មានតំណព័ត៌មានផងដែរក្នុងកិច្ចព្រមព្រៀងនេះ។តំណដែលមានសេចក្ដីជូនដំណឹងនិងលក្ខខណ្ឌជាប់កាតព្វកិច្ចនេះរួមមាន៖

·សេចក្ដីថ្លែងការណ៍ពីភាពឯកជនMicrosoft (aka.ms/privacy)

·កិច្ចព្រមព្រៀងសេវាMicrosoft (aka.ms/msa)

·លក្ខខណ្ឌអាជ្ញាបណ្ណAdobe Flash Player (aka.ms/adobeflash)

************************************************************************

## គ្មានការធានា

សុហ្វវែរលើឧបករណ៍របស់អ្នក (រួមទាំងកម្មវិធី) ត្រូវបានផ្ដល់អាជ្ញាបណ្ណឲ្យ"ដូចដែលមាន"។ក្រោមវិសាលភាពអតិបរមាដែលច្បាប់ក្នុងស្រុករបស់អ្នកអនុញ្ញាតអ្នកយល់ព្រមទទួលហានិភ័យទាំងស្រុងចំពោះគុណភាពនិងប្រសិទ្ធផលនៃរបស់សុហ្វវែរនេះ។បើសុហ្វវែរនេះមានវិការៈអ្នកទទួលរាប់រងចំពោះសោហ៊ុយចំណាយទាំងស្រុងនៃការជួសជុលដែលចាំបាច់ទាំងអស់។ឧស្សាហករនិងMicrosoft មិនផ្ដល់ការធានាការរ៉ាប់រងឬលក្ខខណ្ឌជាក់លាក់ដទៃទៀតសម្រាប់សុហ្វវែរនេះឡើយ។ក្រោមវិសាលភាពដែលច្បាប់ក្នុងស្រុកបានអនុញ្ញាត

ឧស្សាហករនិងMicrosoft ដកចេញនូវការធានាដែលបានបង្កប់ន័យទាំងអស់រួមទាំងការធានាដែលបានបង្កប់ន័យនៃភាពជាទំនិញគុណភាពភាពសមស្របក្នុងគោលបំណងជាក់លាក់និងភាពគ្មានការរំលោភបំពាន។អ្នកអាចមានសិទ្ធិអ្នកប្រើប្រាស់បន្ថែមទៀតឬការធានាតាមផ្លូវច្បាប់ក្រោមច្បាប់ក្នុងស្រុករបស់អ្នកដែលលក្ខខណ្ឌទាំងនេះមិនអាចផ្លាស់ប្តូរ។

បើច្បាប់ក្នុងស្រុករបស់អ្នកដាក់ការធានាឬលក្ខខណ្ឌសូម្បីកិច្ចព្រមព្រៀងនេះមិនមានលក្ខខណ្ឌរបស់វាត្រូវបានកម្រិតត្រឹម 90 ថ្ងៃពីពេលដែលអ្នកប្រើប្រាស់ដំបូងទទួលសុហ្វវែរនេះ។បើឧស្សាហករឬMICROSOFT បំពានលើការធានាឬលក្ខខណ្ឌនោះការកែខៃតែមួយគត់ជូនអ្នកតាមការជ្រើសរើសរបស់ឧស្សាហករឬMICROSOFT គឺ (I) ជួសជុលឬផ្លាស់ប្តូរសុហ្វវែរនេះដោយមិនគិតថ្លៃឬក៏ (II) ប្រគល់សុហ្វវែរនេះត្រឡប់មកវិញ (ឬក៏តាមការជ្រើសរើសរបស់ខ្លួនគឺប្រគល់ត្រឡប់វិញនូវឧបករណ៍ដែលដំឡើងសុហ្វវែរនេះលើនោះ) សម្រាប់ការសងប្រាក់វិញចំពោះចំនួនទឹកប្រាក់ដែលបានបង់បើមាន។ទាំងនេះគឺជាការកែខៃតែមួយគត់ជូនអ្នកសម្រាប់ការបំពានលើការធានាការរ៉ាបរងឬលក្ខខណ្ឌដែលច្បាប់ក្នុងស្រុករបស់អ្នកដាក់បន្ទុកលើ។

ក្រោមវិសាលភាពដែលច្បាប់ក្នុងស្រុករបស់អ្នកហាមប្រាមបើអ្នកមានមូលដ្ឋានណាមួយសម្រាប់ការទាមទារការខូចខាតអ្នកអាចទាមទារពីឧស្សាហករឬMICROSOFT តែចំពោះការខូចខាតដោយផ្ទាល់ដល់ទៅចំនួនទឹកប្រាក់ដែលអ្នកបានបង់សម្រាប់សុហ្វវែរនេះប៉ុណ្ណោះ (ឬដល់ទៅ $50 USD បើអ្នកបានទទួលសុហ្វវែរនេះដោយមិនគិតថ្លៃ)។អ្នកនឹងមិនទាមទារហើយនឹងលះបង់សិទ្ធិក្នុងការទាមទារការជួសជុលការខូចខាតឬការកែខៃផ្សេងទៀតរួមទាំងការខាតបង់ប្រាក់ចំណេញនិងការខូចខាតដោយផ្ទាល់ជាផលវិបាកជាពិសេសដោយប្រយោលឬជាឧប្បត្តិហេតុឡើយក្រោមផ្នែកណាមួយនៃកិច្ចព្រមព្រៀងនេះឬក្រោមទ្រឹស្តីនានា។ដែនកំណត់នេះអនុវត្តចំពោះ (I) អ្វីមួយដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងនេះសុហ្វវែរ (រួមទាំងកម្មវិធី) ឧបករណ៍សេវាការខូចឬការបាត់បង់ទិន្នន័យការខកខានក្នុងការបញ្ជូនឬទទួលទិន្នន័យខ្លឹមព័ត៌មាន (រួមទាំងកូដ) លើវិបសៃអ៊ីនធឺណិតរបស់តតិយភាគីឬកម្មវិធីរបស់តតិយភាគីព្រមទាំង (II) បណ្តឹងសម្រាប់ការបំពានកិច្ចសន្យាការធានាការរ៉ាបរងឬលក្ខខណ្ឌ; ការទទួលខុសត្រូវដាច់ខាតការធ្វេសប្រហែសឬកំហុសរដ្ឋប្បវេណីផ្សេងទៀត; ការបំពានលើឧបញ្ញត្តិច្បាប់ឬបទបញ្ជា; ការកែលម្អមិនត្រឹមត្រូវ; ឬក្រោមទ្រឹស្តីដទៃផ្សេងទៀត។

ការដកចេញនូវខូចខាតនិងដែនកំណត់នៃការកែខៃក្នុងកិច្ចព្រមព្រៀងនេះអនុវត្តសូម្បីអ្នកគ្មានការកែខៃក៏ដោយ (សុហ្វវែរត្រូវបានផ្តល់អាជ្ញាបណ្ណឲ្យ"ដូចដែលមាន") បើការជួសជុលការជំនួសឬការសងប្រាក់វិញ (បើតម្រូវដោយច្បាប់ក្នុងស្រុករបស់អ្នក) មិនសងអ្នកទាំងស្រុងចំពោះការខូចខាតនានាបើឧស្សាហករឬMICROSOFT បានដឹងឬគួរបានដឹងអំពីលទ្ធភាពនៃការខូចខាតនោះឬបើការកែខៃនោះមិនអាចបំពេញតាមគោលបំណងសំខាន់របស់វា។

ប្រើក្សាជាមួយឧស្សាហករឧបករណ៍របស់អ្នកដើម្បីដឹងថាតើឧបករណ៍របស់អ្នកត្រូវបានរ៉ាប់រងដោយការធានាទេ។